ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

***

ឆ្នាំទី ៤ លេខ ៣៩.៤០ ថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ១៩៩៦

រាជកិច្ច

រួមមាន :

- ច្បាប់
- ក្រម-ក្រឹត្យ
- អនុក្រឹត្យ
- ប្រកាស
- សេចក្ដីសំរេច
- សារាចរ

ផ្សាយចេញពីទីស្ដីការគណៈរដ្ឋមន្ត្រីរៀងរាល់សប្ដាហ៍

ក

មាតិកា

I .ខុទ្ទកាល័យព្រះមហាក្សត្រ

ព្រះរាជក្រម

០៩-១០-១៩៩៦- ព្រះរាជក្រម នស/រកម/១០៩៦/៣០ ច្បាប់ស្តីពីសញ្ជាតិ ១៧០១

II -ទីស្តីការគណៈរដ្ឋមន្ត្រី

១_អនុក្រឹត្យ

១៨-១០-១៩៩៦- អនុក្រឹត្យលេខ ៤៣ អនក្រ.បក បំពេញបន្ថែមមាត្រា ២ នៃ អនុក្រឹត្យលេខ ៨៤ អនក្រ ចុះថ្ងៃទី ៣០_១១_១៩៩៥ ស្តីពីប្រតិទិនឈប់សំរាកការងារប្រចាំឆ្នាំ ១៩៩៦ របស់មន្ត្រីរាជការ បុគ្គលិក និយោជិក ១៧០៨

១៨_១០_១៩៩៦_ អនុក្រឹត្យលេខ ៤៤ អនក្រ.បក ស្តីពីការបង្កើត កងពលធំ ថ្មើជើងលេខ ១៥ ១៧០៩

២_សេចក្តីប្រកាស

២៩_១០_១៩៩៦_ សេចក្តីប្រកាសលេខ ០១ សប្រក. សេចក្តីប្រកាសរបស់ រាជរដ្ឋាភិបាលកម្ពុជា ១៧១០

៣_សេចក្តីសំរេច

១៧-១០-១៩៩៦- សេចក្តីសំរេចលេខ ៩២ សសរ ស្តីពីការបង្កើតគណៈកម្មការ ចំរុះសំរាប់ការអនុវត្តន៍ច្បាប់មនុស្សធម៌អន្តរជាតិ ១៧១២

១៧_១០_១៩៩៦_ សេចក្ដីសំរេច លេខ ៤៣ ស.សរ ស្ដីពីការផ្ទេរសិទ្ធិ ១៧១៥

៣_សារាចរ

១៦-១០-១៩៩៦- សារាចរលេខ ០៦ សរ ស្ដីពីការចាត់តាំងរៀបចំពិធីបុណ្យចំរើនព្រះជន្មព្រះករុណាព្រះបាទសម្ដេចព្រះ **នរោត្ដម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ក្នុងគម្រប់ព្រះជន្ម ៧៤ យាងចូល ៧៥ ព្រះវស្សា បុណ្យខួបអនុស្សាវរីយ៍លើកទី ៤៣ នៃទិវាបុណ្យឯករាជ្យជាតិ ៩ វិច្ឆិកា និងបុណ្យអុំទូក បណ្ដែតប្រទីប សំពះព្រះខែ អកអំបុក ១៧១៦

III - ការងារបណ្ដាក្រសួង

ប្រកាសអន្តរក្រសួង

១_ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញកិច្ច និងក្រសួងធម្មការ និងសាសនា

១៧-១០-១៩៩៦- ប្រកាសអន្តរក្រសួងលេខ ៥៧៩ សហវ.មប្រក ស្ដីពីការបង្កើតរជ្ជទេយ្យបុរេប្រទាននៅក្រសួងធម្មការ និងសាសនា ១៧២០

២_ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងផែនការ

២១-១០-១៩៩៦- ប្រកាសអន្តរក្រសួងលេខ ៦១៩ សហវ.មប្រក ស្ដីពីការបង្កើតរជ្ជទេយ្យចំណូលនៅក្រសួងផែនការ ១៧២២

២១_១០_១៩៩៦_ ប្រកាសអន្តរក្រសួងលេខ ៦២០ សហវ.មប្រក ស្ដីពីការតែងតាំងរជ្ជទេយ្យចំណូល នៅក្រសួងផែនការ ១៧២៤

៣_ទីស្ដីការរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

ប្រកាស

១៧_១០_១៩៩៦_ ប្រកាសលេខ ៥៩៥ ផក.ប្រក អនុញ្ញាតអោយលោក គុយ ហេង ជនជាតិខ្មែរសញ្ជាតិកម្ពុជា បើកដំណើរការរោងម៉ាស៊ីនកិនស្រូវ កំលាំង ១២០ សេះ ១៧២៦

១៧_១០_១៩៩៦_ ប្រកាសលេខ ៥៩៦ ផក.ប្រក អនុញ្ញាតអោយលោក សុខ ធឿន ជនជាតិខ្មែរ សញ្ជាតិកម្ពុជា បន្តដំណើរការឧស្សាហកម្មតូចផលិតទឹកកកដើម ១៧២៦

១៧_១០_១៩៩៦_ ប្រកាសលេខ ៥៩៧ ផក.ប្រក អនុញ្ញាតអោយលោក ឃុន កង ជនជាតិខ្មែរ សញ្ជាតិកម្ពុជា បន្តដំណើរការឧស្សាហកម្មតូចផលិតទឹកកកដើម ១៧២៧

១៧_១០_១៩៩៦_ ប្រកាសលេខ ៥៩៨ ផក.ប្រក អនុញ្ញាត្តិអោយលោក គីម កឿន ជនជាតិខ្មែរ សញ្ជាតិកម្ពុជា បើកដំណើរការរោងម៉ាស៊ីនកិនស្រូវ កំលាំង ៦៥ សេះ ១៧២៧

១៧_១០_១៩៩៦_ ប្រកាសលេខ ៥៩៩ ផក.ប្រក អនុញ្ញាតអោយលោក អិន ឡុម ជនជាតិខ្មែរ សញ្ជាតិកម្ពុជា បើកដំណើរការរោងម៉ាស៊ីនកិនស្រូវកំលាំង ៨០សេះ ១៧២៨

១៨_១០_១៩៩៦_ ប្រកាសលេខ ៦០០ផក.ប្រក អនុញ្ញាតិអោយលោក ចេង ជួយ ជនជាតិខ្មែរ សញ្ជាតិកម្ពុជា បើកដំណើរការសិប្បកម្មផលិតថ្នាំស្អុយ «កាល់ស្យូមកាបូ» ១៧២៨

១៨_១០_១៩៩៦_ ប្រកាសលេខ ៦០១ ផក.ប្រក អនុញ្ញាតអោយលោក សុខ ម៉ៅ ជនជាតិខ្មែរ សញ្ជាតិកម្ពុជា បន្តដំណើរការឧស្សាហកម្មតូចផលិតទឹកកកដើម ១៧២៩

១៨_១០_១៩៩៦_ ប្រកាសលេខ ៦០[illegible].ប្រក អនុញ្ញាតអោយលោក ហួត ហ៊ាង ជនជាតិខ្មែរ សញ្ជាតិកម្ពុជា ជាម្ចាស់រោងម៉ាស៊ីនផលិតទឹកកកដើម

ផ្ទេរភារកិច្ចគ្រប់គ្រងជូន «លោក គង់ គឹមហេង » វិញ ១៧២៩

១៨_១០_១៩៩៦_ ប្រកាសលេខ ៦០៣ ផក.ប្រក អនុញ្ញាតលោក គង់ សារ៉ូ ជាម្ចាស់រោងម៉ាស៊ីនផលិតទឹកកកដើម ផ្ទេរភារកិច្ចគ្រប់គ្រងជូនលោក នៅ សារ៉េន វិញ ១៧៣០

១៨_១០_១៩៩៦_ ប្រកាសលេខ ៦០៤ ផក.ប្រក អនុញ្ញាតអោយលោក ប៉ែន សុខា ជនជាតិខ្មែរ សញ្ជាតិកម្ពុជា បើកដំណើរការរោងម៉ាស៊ីនកិនស្រូវកំលាំង ៨០សេះ ១៧៣០

១៨_១០_១៩៩៦_ ប្រកាលលេខ ៦០៥ ផក.ប្រក អនុញ្ញាតអោយលោក អ៊ុំ ហាវ ជនជាតិខ្មែរសញ្ជាតិកម្ពុជាបន្តដំណើរការឡផលិតឥដ្ឋក្បឿង ១៧៣១

១៨_១០_១៩៩៦_ ប្រកាសលេខ ៦០៦ ផក.ប្រក អនុញ្ញាតអោយលោកឯកឧត្តម សុជាន់ណាត ជនជាតិខ្មែរ សញ្ជាតិកម្ពុជា បន្តដំណើរការឧស្សាហកម្មតូចផលិតទឹកកកដើម ១៧៣១

១៨_១០_១៩៩៦_ ប្រកាសលេខ ៦០៧ ផក.ប្រក អនុញ្ញាតអោយលោក សួត គុន ជនជាតិខ្មែរ សញ្ជាតិកម្ពុជា បើកដំណើរការរោងម៉ាស៊ីនកិនស្រូវកំលាំង ២៤សេះ ១៧៣២

១៨_១០_១៩៩៦_ ប្រកាសលេខ ៦០៨ ផក.ប្រក អនុញ្ញាតអោយអ្នកស្រី ប៉ោង គឹមយន ជនជាតិខ្មែរ សញ្ជាតិកម្ពុជា បន្តដំណើរការឧស្សាហកម្មតូចផលិតទឹកកកដើម ១៧៣២

២១_១០_១៩៩៦_ ប្រកាសលេខ ៦០៩ ផក.ប្រក អនុញ្ញាតអោយលោក ស ស្រ៊ានគ្រុយ ជនជាតិខ្មែរ សញ្ជាតិកម្ពុជា បន្តដំណើរការឧស្សាហកម្មតូចផលិតទឹកកកដើម ១៧៣៣

២២_១០_១៩៩៦_ ប្រកាសលេខ ៦១០ ផក.ប្រក អនុញ្ញាតអោយលោក ជា ពៅ ជនជាតិខ្មែរ សញ្ជាតិកម្ពុជា បើកដំណើរការមូលដ្ឋានគ្រួស ខ្សាច់ ១៧៣៣

២២_១០_១៩៩៦_ ប្រកាសលេខ ៦១១ ផក.ប្រក អនុញ្ញាតអោយលោក មួន វណ្ណា ជនជាតិខ្មែរ សញ្ជាតិកម្ពុជា បន្តដំណើរការសិប្បកម្មផលិតស្រាកែច្នៃស្រា «ដូងទឹក អាញី » ១៧៣៤

២២_១០_១៩៩៦_ ប្រកាសលេខ ៦១២ ផក.ប្រក អនុញ្ញាតអោយលោក តាំង អាន ជនជាតិខ្មែរ សញ្ញាតិកម្ពុជា បើកដំណើរការសិប្បកម្មផលិតទៀន យីហោ «គីម លី» ១៧៣៤
២២_១០_១៩៩៦_ ប្រកាសលេខ ៦១៣ ផក.ប្រក អនុញ្ញាតអោយលោក ទុង រតនា ជនជាតិខ្មែរ បើកដំណើរការសិប្បកម្មកាត់ដេរសំលៀកបំពាក់ ១៧៣៥
២២_១០_១៩៩៦_ ប្រកាសលេខ ៦១៤ ផក.ប្រក អនុញ្ញាតអោយអ្នកស្រី អួច ស៊ីវ ជនជាតិខ្មែរ សញ្ញាតិកម្ពុជា បើកដំណើរការឧស្សាហកម្មតូចផលិតទឹកបរិសុទ្ធ សញ្ញា « TURIST » ១៧៣៥
២៩_១០_១៩៩៦_ ប្រកាសលេខ ៦២០ ផក.ប្រក អនុញ្ញាតអោយ ក្រុមហ៊ុន សាន់ណា ហ្វីស៊ើរី (SUN NAH FISHERIS CO.LTD) តំណាងដោយលោក CHOI KOON SHUN សញ្ញាតិអង់គ្លេស បង្កើតរោងចក្របង្គក ១៧៣៦

៤_ទីស្តីការរដ្ឋមន្ត្រីក្រសួងពត៌មាន

ប្រកាស

១៦_១០_១៩៩៦_ ប្រកាសលេខ ២៨៣/៩៦ ពម.ប្រក អនុញ្ញាតអោយផ្ទេរសិទ្ធិចាងហ្វាងការផ្សាយកាសែត «CAMBODIA TODAY» ពីលោក ធី ម៉ូហាន មកលោក CHO SING KOO វិញ ១៧៣៧
១៦_១០_១៩៩៦_ ប្រកាសលេខ ២៨៤/៩៦ ពម.ប្រក ស្តីពីការតែងតាំងមន្ត្រីរាជការ ១៧៣៨
១៨_១០_១៩៩៦_ ប្រកាសលេខ ២៨៦/៩៦ ពម.ប្រក អនុញ្ញាតអោយផ្ទេរសិទ្ធិចាងហ្វាងការផ្សាយកាសែត «សេរីភាពថ្មី» ពីលោក ហែន វិភាគ មកលោក សោម វិរៈ វិញ ១៧៣៩
២៥_១០_១៩៩៦_ ប្រកាសលេខ ២៩៣/៩៦ ពម.បល.ប្រក ស្តីពីការតែងតាំងមន្ត្រីរាជការ ១៧៤១

២៩_១០_១៩៩៦_ ប្រកាសលេខ ២៩៤/៩៦ ពម. បល. ប្រក អនុញ្ញាតអោយ ប្តូរឈ្មោះសារពត៌មានពី (LE QUOTIDIEN DU CAMBODGE) មកជាព្រឹត្តិប័ត្រខ្មែរដំណឹង KHMER INFO វិញ ១៧៤២

៥_ទីស្តីការរដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន

ប្រកាស

២១_១០_១៩៩៦_ ប្រកាសលេខ ៣៩២ ប្រក. សក ស្តីពីការកំរិតកំណត់តំលៃកត់ត្រា ១៧៤៣
២១_១០_១៩៩៦_ ប្រកាសលេខ ៣៩៣ ប្រក. សក ស្តីពីការកំណត់ថ្ងៃឈ្នួលភ្នាក់ងារ ១៧៤៦
២១_១០_១៩៩៦_ ប្រកាសលេខ ៣៩៤ ប្រក. សក ស្តីពីការកំណត់តំលៃបន្ថែម ១៧៥២

៦_ទីស្តីការរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

ប្រកាស

១៧_១០_១៩៩៦_ ប្រកាសលេខ ៨៧១ អយក. ប្រក ស្តីពីការពង្រីកអនុវិទ្យាល័យ កោះអណ្តែត ទៅជាវិទ្យាល័យកោះអណ្តែត ក្នុងស្រុកកោះអណ្តែត ខេត្តតាកែវ ១៧៥៤
១៧_១០_១៩៩៦_ ប្រកាសលេខ ៨៧៣ អយក. ប្រក ស្តីពីការប្តូរឈ្មោះវិទ្យាល័យ ស្គន់ ទៅជាវិទ្យាល័យ ហ៊ុន សែន ស្គន់ ស្ថិត ក្នុងស្រុកជើងព្រៃ ខេត្តកំពង់ចាម ១៧៥៥
១៧_១០_១៩៩៦_ ប្រកាសលេខ ៨៧៤ អយក. ប្រក ស្តីពីការពង្រីក និងប្តូរឈ្មោះ អនុវិទ្យាល័យមេមត់ ទៅជាវិទ្យាល័យ ប៊ុន រ៉ានី ហ៊ុន សែន មេមត់ ស្ថិតក្នុងស្រុកមេមត់ ខេត្តកំពង់ចាម ១៧៥៧

១៧_១០_១៩៩៦_ ប្រកាសលេខ ៨៧៥ អយក.ប្រក ស្តីពីការប្តូរឈ្មោះវិទ្យាល័យ ពញាក្រែក ទៅជាវិទ្យាល័យ **ហ៊ុន សែន** ពញាក្រែក ស្ថិតក្នុងស្រុក ពញាក្រែក ខេត្តកំពង់ចាម ១៧៥៨

១៧_១០_១៩៩៦_ ប្រកាសលេខ ៨៧៦ អយក.ប្រក ស្តីពីការពង្រីក និងប្តូរឈ្មោះអនុវិទ្យាល័យស្វាគូ ទៅជាវិទ្យាល័យ **ហ៊ុន សែន** ស្វាគូ ស្ថិតក្នុងស្រុកសំរោង ខេត្តតាកែវ ១៧៦០

១៧_១០_១៩៩៦_ ប្រកាសលេខ ៨៨០ អយក.ប្រក ស្តីពីការបើកអនុវិទ្យាល័យសម្តេចក្រុមព្រះ **នរោត្តម រណឫទ្ធិ** ក្នុងស្រុកកោះសូទិន ខេត្តកំពង់ចាម ១៧៦១

១៧_១០_១៩៩៦_ ប្រកាសលេខ ៨៨១ អយក.ប្រក ស្តីពីការបើកអនុវិទ្យាល័យព្រែកតានង់ ក្នុងស្រុកកោះសូទិន ខេត្តកំពង់ចាម ១៧៦៣

១៧_១០_១៩៩៦_ ប្រកាសលេខ ៨៨៥ អយក.ប្រក ស្តីពីការអនុញ្ញាតអោយបោះពុម្ពសៀវភៅឧបសម្ព័ន្ធគំនូស និង ការត្រៀមកុមារអោយហាត់សរសេរផ្នែកមត្តេយ្យសិក្សា សំរាប់គ្រូ ១៧៦៤

៧_ឧិស្តីការរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

ប្រកាស

១៦_១០_១៩៩៦_ ប្រកាសលេខ ៥៦៧ ប្រកកសក.ចត ស្តីពីការតែងតាំងតម្លើងឋានៈមន្ត្រីរាជការ ១៧៦៥

៨_ឧិស្តីការរដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ

ប្រកាស

១៨_១០_១៩៩៦_ ប្រកាសលេខ ២០៥ ប្រក.វវស.បុ ស្តីពីការទទួលស្គាល់លទ្ធផលនៃការប្រឡងសញ្ញាប័ត្រសិល្បៈនិងស្នាតកប័ត្រសិល្បៈឆ្នាំ១៩៩៥_៩៦ ១៧៦៧

៩_ទីស្តីការរដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ

ប្រកាស

២៤_១០_១៩៩៦_ ប្រកាសលេខ ២០៥៣ ប្រក.អជប ស្តីពីការបង្កើតក្រុមការងារសំរាប់គំរោងអភិវឌ្ឍន៍កសិកម្ម និងជំនួយបច្ចេកទេសក្រោមឥណទានធនាគារអភិវឌ្ឍន៍អាស៊ី ១៧៧៣

១០_ទីស្តីការរដ្ឋមន្ត្រីក្រសួងយុត្តិធម៌

ប្រកាស

២២_១០_១៩៩៦_ ប្រកាសលេខ ៦៣ ប្រក.បល ៩៦ ផ្ទេរភារកិច្ចលោក គឹម ឆេងប៊ុន ១៧៧៥
២៨_១០_១៩៩៦_ ប្រកាសលេខ ៦៥ ប្រក.បល ៩៦ ស្តីពីការផ្ទេរភារកិច្ចកញ្ញា ហេង ផល្លា ១៧៧៦
២៩_១០_១៩៩៦_ ប្រកាសលេខ ៦៧ ប្រក.បល ៩៦ ស្តីពីការផ្ទេរភារកិច្ចលោក កែវ ចាន់វាសនា ១៧៧៧

១១_ទីស្តីការក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍

ប្រកាស

២២_១០_១៩៩៦_ ប្រកាសលេខ ១៧៦ បទ.ប្រក ស្តីពីការតែងតាំងមន្ត្រីរាជការ ១៧៧៨

១២_ទីស្តីការក្រសួងធម្មការ និងសាសនា

សេចក្តីសំរេច

២៥_១០_១៩៩៦_ សេចក្តីសំរេចលេខ ២២១/៩៦ កធស អនុញ្ញាតច្បាប់ជាគោលការណ៍អោយបើកស្នាក់ការថ្វាយបង្គំព្រះសាសនាគិស្ទឈ្មោះ «ស្នាក់ការត្រៃស្ថាន»នៅភូមិ ២ ឃុំកំពង់ស្វាយ ស្រុកសេរីសោភ័ណ» ១៧៧៩
២៩_១០_១៩៩៦_ សេចក្តីសំរេចលេខ ២២៤/៩៦ កធស អនុញ្ញាតច្បាប់ជាគោលការណ៍អោយបើកព្រះវិហារចិនឈ្មោះ «ព្រះវិហារសាសនាសង្គ្រោះព្រះនាងគង់ ស៊ីអ៊ុម នៅសង្កាត់ផ្សារដើមគរ ខ័ណ្ឌទួលគោក» ១៧៨១

I - ខុទ្ទកាល័យព្រះមហាក្សត្រ

ព្រះរាជក្រម

ព្រះរាជក្រម នស/រកម ១០៩៦/៣០

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន រាជហរិវង្ស

ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍ និករោត្តម

ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ ព្រះចៅក្រុង

កម្ពុជាធិបតី

* * *

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ២៩ ខែ កញ្ញា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រីទី ១ និងនាយករដ្ឋមន្ត្រីទី ២
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ នស.៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការ រៀបចំនិងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យ លេខ នស.រកត.១០៩៤/៨៣ចុះថ្ងៃទី ២៤ ខែ តុលាឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស.រកត.១០៩៤/៩០ចុះថ្ងៃទី ៣១ ខែ តុលាឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស.រកម.០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- តាមសេចក្តីក្រាបបង្គំទូលស្នើសុំអំពីសម្តេចនាយករដ្ឋមន្ត្រីទាំងពីរ និងអំពីសហរដ្ឋមន្ត្រីក្រសួង មហាផ្ទៃ

ប្រកាសឱ្យប្រើ

ច្បាប់ ស្ដីពីសញ្ជាតិ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ២០ សីហា ឆ្នាំ ១៩៨៦ នាសម័យប្រជុំ វិសាមញ្ញ នីតិកាលទី១ ដែលមានសេចក្ដីទាំងស្រុងដូចតទៅ ÷

ច្បាប់

ស្ដីពី

សញ្ជាតិ

ជំពូកទី ១

បទបញ្ញត្តិទូទៅ

មាត្រា ១ ._

ច្បាប់នេះមានគោលដៅកំណត់សញ្ជាតិខ្មែរ ចំពោះជនដែលបំពេញល័ក្ខខ័ណ្ឌ នៃច្បាប់នេះ ដែលរស់នៅលើទឹកដី នៃព្រះរាជាណាចក្រកម្ពុជា ឬ នៅបរទេស ។

មាត្រា ២ ._

ជនណាមានសញ្ជាតិខ្មែរ ជាប្រជាពលរដ្ឋខ្មែរ ។ ប្រជាពលរដ្ឋខ្មែរមិនអាចត្រូវបានដកសញ្ជាតិ និរទេស ឬ ចាប់បញ្ជូនខ្លួនទៅឱ្យប្រទេសក្រៅណាមួយឡើយ លើកលែងតែមានកិច្ចព្រមព្រៀងជាមួយគ្នាទៅវិញទៅមក ។

មាត្រា ៣ ._

ប្រជាពលរដ្ឋខ្មែរដែលកំពុងរស់នៅឯបរទេស ÷

១_ត្រូវបានរដ្ឋគាំពារតាមគ្រប់មធ្យោបាយការទូត

២_មិនអាចបាត់បង់សញ្ជាតិដោយឯងឯង ។

ជំពូកទី ២

សញ្ជាតិខ្មែរពីកំណើត

មាត្រា ៤ ._

១_ត្រូវបានសញ្ជាតិខ្មែរ ទោះបីកើតនៅទីណាក៏ដោយ ÷

_កូនមានខាន់ស្លាដែលកើតមកពីឪពុក ឬ ម្ដាយមានសញ្ជាតិខ្មែរ ឬ

_កូនឥតខាន់ស្លាដែលកើតមកពីឪពុក ឬម្តាយមានសញ្ជាតិខ្មែរទទួលស្គាល់ឬ

_កូនដែលឪពុក ម្តាយមិនទទួលស្គាល់ កាលបើតុលាការបានចេញសាលក្រមថា កូននោះពិតជាកើតពីឪពុក ឬ ម្តាយដែលមានសញ្ជាតិខ្មែរ ។

២_ត្រូវបានសញ្ជាតិខ្មែរ ដោយកើតនៅក្នុងព្រះរាជាណាចក្រកម្ពុជា ÷

ក_កូនដែលកើតពីឪពុកនិងម្តាយបរទេស ដែលកើតនិងរស់នៅស្របច្បាប់ក្នុងព្រះរាជាណាចក្រកម្ពុជា ។

ខ_កូនដែលកើតពីឪពុក ម្តាយមិនស្គាល់ និងកូនទើបនឹងកើតដែលគេរើសបាននៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវចាត់ទុកថា កើតនៅក្នុងព្រះរាជាណាចក្រកម្ពុជាដែរ ។

ជំពូកទី ៣

សញ្ជាតិខ្មែរដោយអាពាហ៍ពិពាហ៍

មាត្រា ៥ .–

ស្ត្រី ឬ បុរសបរទេសដែលយកប្តី ឬប្រពន្ធខ្មែរ ដោយបានរៀបអាពាហ៍ពិពាហ៍ អាចទាមទារ សញ្ជាតិខ្មែរបាន លុះណាតែស្ត្រី ឬបុរសនោះរស់នៅជាមួយគ្នារយៈពេលបីឆ្នាំ ក្រោយពេលចុះសំបុត្រអាពាហ៍ពិពាហ៍ ។

បែបបទនិងនីតិវិធីនៃការទាមទារសញ្ជាតិខ្មែរ ត្រូវកំណត់ដោយអនុក្រឹត្យ ។

ការផ្តល់សញ្ជាតិខ្មែរ តាមករណីទាមទារសញ្ជាតិ ត្រូវសំរេចដោយព្រះរាជក្រឹត្យ ។

មាត្រា ៦ .–

ប្រជាពលរដ្ឋខ្មែរមិនបាត់សញ្ជាតិខ្មែរ ដោយសារការរៀបអាពាហ៍ពិពាហ៍ជាមួយជនបរទេសទេ ។

ជំពូកទី ៤

សញ្ជាតូបនីយកម្ម

មាត្រា ៧ .–

ជនបរទេសអាចសុំចូលសញ្ជាតិខ្មែរបាន ដោយសញ្ជាតូបនីយកម្ម ។

សញ្ជាតូបនីយកម្មមិនមែនជាសិទ្ធិរបស់អ្នកស្នើសុំឡើយ គឺជាការអនុគ្រោះរបស់ព្រះរាជាណាចក្រកម្ពុជាតែប៉ុណ្ណោះ ។ នោះក្នុងប្រការណាក៏ដោយពាក្យសុំនោះអាចត្រូវបដិសេធចោលបានតាមអំណាចឆន្ទានុសិទ្ធិ ។

មាត្រា ៨ .–

ជនបរទេសដែលអាចសុំសញ្ជាតូបនីយកម្មបាន ត្រូវបំពេញល័ក្ខខ័ណ្ឌដូចតទៅ ÷

១_មានលិខិតបញ្ជាក់ថា មានគំនិតមារយាទនិងសីលធម៌ល្អ ដែលចេញឱ្យដោយមេឃុំ ឬ ចៅសង្កាត់ នៃទីលំនៅរបស់ខ្លួន

២_មានលិខិតថ្កោលទោសបញ្ជាក់ថា ពុំដែលមានទោស ពីបទព្រហ្មទ័ណ្ឌ ណាមួយ

៣_មានលិខិតបញ្ជាក់ថា ជននោះមានទីលំនៅក្នុងព្រះរាជាណាចក្រកម្ពុជា ហើយស្នាក់នៅជាប់ចំនួនប្រាំពីរឆ្នាំ ដោយគិតពីថ្ងៃដែលបានទទួលប័ណ្ណស្នាក់នៅដែលចេញអោយ ក្នុងក្របខ័ណ្ឌ នៃច្បាប់ស្តីពីអន្តោប្រវេសន៍

៤_ មានទីលំនៅក្នុងព្រះរាជាណាចក្រកម្ពុជា នៅពេលដាក់ពាក្យសុំសញ្ជាតូបនីយកម្ម

៥_ ចេះនិយាយភាសាខ្មែរ ចេះអក្សរខ្មែរ និងយល់ដឹងប្រវត្តិសាស្ត្រខ្មែរខ្លះៗ ហើយបង្ហាញភស្តុតាងច្បាស់ថា ខ្លួនអាចរស់នៅក្នុងសង្គមខ្មែរបានដោយសុខដុមព្រមទាំងទទួល បាននូវទំនៀម ទំលាប់និងប្រពៃណីល្អរបស់ខ្មែរ

៦_ មានបញ្ញានិងកាយសម្បទាដែលមិននាំឱ្យមានគ្រោះថ្នាក់ ឬ នាំឱ្យមានបន្ទុកដល់ជាតិ ។

មាត្រា ៩ .–

ចំពោះជនបរទេសណាដែលកើតក្នុងព្រះរាជាណាចក្រកម្ពុជា រយៈពេលស្នាក់នៅជាប់ចំនួន ប្រាំពីរឆ្នាំ ដូចមានចែងក្នុងចំណុចទី ៣ មាត្រា ៨ នៃច្បាប់នេះត្រូវបន្ថយមកនៅបីឆ្នាំវិញ ។

មាត្រា ១០ .–

ចំពោះជនបរទេសណា ដែលបានទទួលលិខិតអនុញ្ញាតឱ្យវិនិយោគពីក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ហើយដែលបានអនុញ្ញាតគំរោងដាក់ស្តែងចំណាយទុនចំនួន ចាប់ពីមួយពាន់ពីររយហាសិបលានរៀល (១.២៥០.០០០.០០០រៀល) ឡើងទៅរយៈពេលស្នាក់នៅ ដូចមានចែងក្នុងចំណុចទី៣ មាត្រា ៨ នៃច្បាប់នេះត្រូវបានលើកលែង ។

មាត្រា ១១ .–

ចំពោះជនបរទេសណា ដែលពុំមានលិខិតអនុញ្ញាតពីក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា តែបាន ទទួលការអនុញ្ញាតត្រឹមត្រូវតាមច្បាប់ ហើយដែលបានចំណាយទុនវិនិយោគ ចាប់ពីចំនួនមួយពាន់ពីររយហា សិបលានរៀល (១.២៥០.០០០.០០០រៀល) ឡើង ទៅរយៈពេលស្នាក់នៅដែលមានចែងក្នុងចំណុច ទី ៣ មាត្រា ៨ នៃច្បាប់នេះត្រូវ បានលើកលែង ។

មាត្រា ១២ .–

ជនបរទេសណាដែលបានធ្វើអំណោយជាប្រាក់ដល់ថវិកាជាតិចាប់ពីមួយពាន់លាន រៀល (១.០០០.០០០.០០០រៀល) ឡើងទៅ សំរាប់ជាផលប្រយោជន៍ដល់ការស្តារ និងកសាងសេដ្ឋកិច្ចនៃព្រះរាជាណាចក្រកម្ពុជា ជនបរទេសនោះ អាចធ្វើពាក្យសុំចូល សញ្ជាតិខ្មែរបាន ក្នុងករណីដែលជននោះបាន បំពេញល័ក្ខខ័ណ្ឌដូចមានចែងក្នុង ចំណុចទី ១, ទី ២, ទី ៥, និងទី ៦ មាត្រា ៨ នៃច្បាប់នេះ ។

មាត្រា ១៣ .–

ជនបរទេសដែលបានបង្ហាញនូវភស្តុតាងថា ខ្លួនបានផ្តល់គុណសម្បត្តិពិសេស ឬ ថ្វីដៃ ពិសេសអ្វីមួយជាប្រយោជន៍ដល់ព្រះរាជាណាចក្រកម្ពុជា អាចធ្វើពាក្យសុំចូល សញ្ជាតិខ្មែរបានដោយពុំចាំបាច់ បំពេញល័ក្ខខ័ណ្ឌដូចមានចែងក្នុងចំណុចទី ៣ មាត្រា ៨ នៃច្បាប់នេះ ។

មាត្រា ១៤ .–

ជនបរទេសដែលមានសហព័ទ្ធ ឬ កូនដែលមានអាយុតិចជាង ១៨ ឆ្នាំ ដែលមាន បំណង សុំសញ្ជាតិខ្មែរ អាចសុំសញ្ជាតូបនីយកម្មជាចង្កោមគ្រួសារ ។

មាត្រា ១៥ .–

ជនបរទេសអាចសុំដូរផ្លាស់ឈ្មោះជាខ្មែរបាន ។ ក្នុងករណីនេះត្រូវសរសេរបញ្ជាក់ ឈ្មោះនោះ ក្នុងពាក្យសុំសញ្ជាតូបនីយកម្មរបស់ខ្លួន ។

មាត្រា ១៦ .–

សញ្ជាតូបនីយកម្មដែលផ្តល់ចំពោះជនណាម្នាក់ ត្រូវសំរេចដោយព្រះរាជក្រឹត្យ ។ បែបបទនិងនីតិវិធីនៃការសុំសញ្ជាតូបនីយកម្ម ត្រូវកំណត់ដោយអនុក្រឹត្យ ។

មាត្រា ១៧ ._

ជនដែលបានអនុញ្ញាតឱ្យចូលជាសញ្ជាតិខ្មែរ ត្រូវធ្វើសម្បថនៅចំពោះមុខតុលាការកំពូល ។

ខ្លឹមសារនៃសម្បថនេះមានចែងនៅក្នុងអនុក្រឹត្យ ។

ជំពូកទី ៥

ការបាត់សញ្ជាតិខ្មែរ

មាត្រា ១៨ ._

ជនណាដែលបាត់សញ្ជាតិខ្មែរ ហើយមានអាយុ ១៨ឆ្នាំយ៉ាងតិច អាចសុំលះបង់សញ្ជាតិខ្មែរបាន ក្នុងករណីដែលជននោះមានសញ្ជាតិមួយផ្សេងទៀត និងដោយគ្មានការបង្ខិតបង្ខំ ។

នីតិវិធី និងលក្ខខ័ណ្ឌនៃការសុំលះបង់សញ្ជាតិ ត្រូវកំណត់ដោយអនុក្រឹត្យ ។

ជំពូកទី ៦

ទោសប្បញ្ញត្តិ

មាត្រា ១៩ ._

មានតែប្រជាពលរដ្ឋខ្មែរទេ ទើបមានសិទ្ធិទទួល និង កាន់កាប់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ និងលិខិតឆ្លងដែននៃព្រះរាជាណាចក្រកម្ពុជា ។

មាត្រា ២០ ._

ជនបរទេសណា ដែលកាន់កាប់និងប្រើប្រាស់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ឬ លិខិតឆ្លងដែននៃព្រះរាជាណាចក្រកម្ពុជា ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៥ឆ្នាំ ដល់ ១០ឆ្នាំ ។

មាត្រា ២១ ._

ជនណាដែលក្លែង ធ្វើការកោស លុប សរសេរត្រួត ឬ ឱ្យគេខ្ចី ឬ មួយសរសេរឈ្មោះក្លែងក្លាយនៅក្នុងអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ឬ លិខិតឆ្លងដែន នៃ

ព្រះរាជាណាចក្រកម្ពុជា ឬ មួយប្រើប្រាស់ ឯកសារទាំងនោះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៥ឆ្នាំ ដល់ ១០ឆ្នាំ ។

មាត្រា ២២ .-

មន្ត្រី ភ្នាក់ងាររាជការ ឬ ជនណាដែលសមគំនិត ជួយលាក់បាំង ឬ ផ្តល់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ឬ លិខិតឆ្លងដែនឱ្យជនណាម្នាក់ដែលគ្មាន សញ្ជាតិខ្មែរ ត្រូវផ្តន្ទាទោសដូចគ្នានឹងជនដែល កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ឬ លិខិតឆ្លងដែនដោយខុសច្បាប់ ដូចមានចែងក្នុងមាត្រា ២០ និងមាត្រា ២១នៃច្បាប់នេះ ។

ជំពូកទី ៧

អវសានប្បញ្ញត្តិ

មាត្រា ២៣ .-

បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ១៩៩៦

ព្រះហស្តលេខា

នរោត្តម សីហនុ

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

នាយករដ្ឋមន្ត្រីទី ១	នាយករដ្ឋមន្ត្រីទី ២
ព្រះហស្តលេខានិងត្រា	ហត្ថលេខា និងត្រា
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

បានបង្គំទូលថ្វាយ និងជំរាបជូន

សម្តេចនាយករដ្ឋមន្ត្រីទី ១ និងទី ២

សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

ហត្ថលេខា និង ត្រា

ស ខេង **យូ ហុកគ្រី**

* * *

II- ទីស្ដីការគណៈរដ្ឋមន្ត្រី

១_អនុក្រឹត្យ

រាជធានីភ្នំពេញ ,ថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ១៩៩៦

អនុក្រឹត្យលេខ : ៤៣ អនក្រ.បក

បំពេញបន្ថែមមាត្រា ២ នៃអនុក្រឹត្យ ៨៤ អនក្រ.ចុះថ្ងៃទី ៣០/១១/៩៥ ស្ដីពីប្រតិទិនឈប់សំរាកការងារប្រចាំ ឆ្នាំ ១៩៩៦ របស់មន្ត្រី រាជការ បុគ្គលិក និយោជិក

* * *

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្ដេចព្រះ **នរោត្ដម សីហនុវរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល
- បានឃើញច្បាប់ ស្ដីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- យោងអនុក្រឹត្យលេខ ៨៤ អនក្រ ចុះថ្ងៃទី ៣០ វិច្ឆិកា ឆ្នាំ ១៩៩៥ ស្ដីពីប្រតិទិនឈប់សំរាកការងារប្រចាំឆ្នាំ ១៩៩៦
- យោងអនុក្រឹត្យលេខ ២១ អនក្រ.ចុះថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ១៩៩៦ ស្ដីពីការឈប់សំរាកការងារប្រចាំសប្ដាហ៍ របស់មន្ត្រី រាជការ បុគ្គលិក កម្មករ និយោជិក

សំរេច

មាត្រា ១ : បំពេញបន្ថែមវាក្យខ័ណ្ឌមួយថ្មីក្នុងមាត្រា ២ នៃអនុក្រឹត្យលេខ ៨៤ អនក្រ.ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ ដូចមានខ្លឹមសារខាងក្រោម ÷

ពេលវេលាឈប់ទាំងឡាយ ដែលត្រូវប៉ះចំថ្ងៃសៅរ៍ និងថ្ងៃអាទិត្យ ត្រូវបានអនុញ្ញាត អោយឈប់តែចំនួន ០១ ថ្ងៃ នៃថ្ងៃបន្ទាប់ជាជំនួស ។

មាត្រា ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីគ្រប់ក្រសួង រដ្ឋលេខាធិការគ្រប់រដ្ឋ លេខាធិការដ្ឋានត្រូវទទួលអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្ថលេខា និង ចុះហត្ថ លេខាតទៅ ។

នាយករដ្ឋមន្ត្រីទី ១ **នាយករដ្ឋមន្ត្រីទី ២**

ព្រះហស្ថលេខានិងត្រា ហត្ថលេខានិងត្រា

នរោត្តម រណឫទ្ធិ **ហ៊ុន សែន**

* * *

រាជធានីភ្នំពេញ ,ថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ១៩៩៦

អនុក្រឹត្យលេខ : ៤៤ អនក្រ.ចក

ស្តីពីការបង្កើត កងពលធំថ្មើរជើងលេខ ១៥

* * *

រាជរដ្ឋាភិបាល

_ បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

_ បានឃើញព្រះរាជក្រឹត្យរបស់ព្រះបាទសម្តេចព្រះ **នរោត្តម សីហនុវរ្ម័ន** ព្រះចៅក្រុងកម្ពុជាធិបតី ចុះថ្ងៃទី ២៤ ខែ កក្កដា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំង នាយករដ្ឋមន្ត្រីទី ១ និង នាយករដ្ឋមន្ត្រីទី ២ នៃរាជរដ្ឋាភិបាលកម្ពុជា

_ បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល កម្ពុជា

_ បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី ចុះថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤

_ បានឃើញព្រះរាជក្រម ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើត ក្រសួងការពារជាតិ

- យោងតាមសេចក្តីរបស់រាជរដ្ឋាភិបាល លេខ ៤០ សសរ ចុះថ្ងៃទី ២៦ ខែ កញ្ញា ឆ្នាំ ១៩៩៦ ស្តីពីសមាហរណកម្មកំលាំងដាច់ខ្លួនខ្មែរក្រហមចូល កងយោធពលខេមរភូមិន្ទ
- យោងតាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងការពារជាតិ

សំរេច

មាត្រា ១ : ត្រូវបានបង្កើតមួយកងពលថ្មើរជើងដោយយកសញ្ញាសំគាល់ជា កងពលធំថ្មើរជើង លេខ ១៥ ដាក់ចំណុះផ្ទាល់យោធភូមិភាគទី ៤ ។

មាត្រា ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងការពារជាតិ នាយអគ្គសេនាធិការ នៃកងយោធពលខេមរភូមិន្ទ រដ្ឋមន្ត្រីក្រសួងពាក់ព័ន្ធត្រូវអនុវត្ត អនុក្រឹត្យនេះ ដែលចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខា និងចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី ១ នាយករដ្ឋមន្ត្រីទី ២
ព្រះហស្តលេខា និងត្រា ហត្ថលេខា និងត្រា
នរោត្តម រណឫទ្ធិ **ហ៊ុន សែន**

* * *

២_សេចក្តីប្រកាស

រាជធានីភ្នំពេញ, ថ្ងៃទី ២៩ ខែ តុលា ឆ្នាំ ១៩៩៦

សេចក្តីប្រកាស លេខ : ០១ សប្រក

របស់រាជរដ្ឋាភិបាលកម្ពុជា

* * *

នៅក្នុងនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា ព្រៃឈើ ត្រូវបានចាត់ទុកជាភោគទ្រព្យធម្មជាតិមួយយ៉ាងសំខាន់របស់ប្រទេសជាតិ ដែលទាមទារអោយមានជាចាំបាច់នូវការគ្រប់គ្រង និងការថែរក្សាការពារយ៉ាងហ្មត់ចត់បំផុត ។

កន្លងមកក៏ដូចជាបច្ចុប្បន្ននេះ បាតុភាពលួចកាប់បំផ្លាញឈើថ្មី និងការលួចនាំចេញដោយល្មើសច្បាប់នៅតាមបណ្តោយព្រំដែន តែងតែកើតមានក្នុងកំរិតមួយគួរអោយព្រួយបារម្ភណ៍ ទោះបីជារាជរដ្ឋាភិបាលកម្ពុជា បានប្តេជ្ញាចិត្តចាត់គ្រប់វិធានការ រួមទាំងការធ្វើកិច្ចសហប្រតិបត្តិការយ៉ាងជិតស្និទ្ធ ជាមួយប្រទេសជាមិត្តជិតខាង ដើម្បីទប់ស្កាត់ក៏ដោយ ។

បាតុភាពអសកម្មក្នុងវិស័យព្រៃឈើនៅកម្ពុជា បាននិងកំពុងក្លាយទៅជាចំណុចចាប់អារម្មណ៍ ជាពិសេសរបស់ជាតិ និងអន្តរជាតិ ។

ចំពោះមុខសភាពការណ៍នេះ យោងតាមស្មារតីអង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រីនាថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៦ រាជរដ្ឋាភិបាលកម្ពុជា សូមប្រកាសជាឱឡារិក ដូចតទៅ ÷

១_អនុម័តនយោបាយវាយតម្លៃព្រៃឈើ (Forestry Policy Assessment) ដែលស្នើដោយអង្គការ WORLD BANK , FAO និង UNDP ។

២_អនុម័តច្បាប់ព្រៃឈើ Forestry Code ដែលស្នើដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

៣_មិនអនុញ្ញាតជាដាច់ខាត អោយបណ្តាក្រុមហ៊ុន នាំចេញឈើតាមបណ្តោយព្រំដែនកម្ពុជា_ថៃ ស្ថិតក្នុងតំបន់អសន្តិសុខ ដែលត្រួតពិនិត្យមិនបាន ចាប់តាំងពីថ្ងៃចុះហត្ថលេខាតទៅ ។

៤_ចំពោះឈើចាស់ដែលនៅសេសសល់ ក្រោយថ្ងៃឱសានវាទ (៣០ ខែ មេសា ឆ្នាំ ១៩៩៥) បណ្តាក្រុមហ៊ុនធ្វើអាជីវកម្មព្រៃឈើមានសិទ្ធិនាំចេញ ប៉ុន្តែត្រូវគោរពតាមបែបបទជាធរមាន ដែលមានចែងក្នុងប្រកាសរួម ចុះថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ ១៩៩៦ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងសេចក្តីជូនដំណឹងរបស់ទីស្តីការគណៈរដ្ឋមន្ត្រីលេខ ១១៦០ ចុះថ្ងៃទី ១០ ខែ តុលា ឆ្នាំ ១៩៩៦ ហើយត្រូវធ្វើការនាំចេញ មិនអោយហួសពីថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៦ ជាកំហិត ។

៥_ការនាំចេញឈើនេះ ត្រូវមានការតាមដានត្រួតពិនិត្យ ដោយមានកិច្ចសហប្រតិបត្តិការពីក្រុមហ៊ុនជំនាញឯកទេសល្បីឈ្មោះ ។

៦_រាជរដ្ឋាភិបាលកម្ពុជា សង្ឃឹមនិងជឿជាក់លើការបន្តជួយឧបត្ថម្ភគាំទ្រជានិច្ចដល់កិច្ចសហប្រតិបត្តិការដ៏ល្អប្រពៃរវាងព្រះរាជាណាចក្រកម្ពុជា ជាមួយបណ្តាប្រទេសជិតខាង ដើម្បីបន្តជួយទប់ស្កាត់ការលួចកាប់ឈើថ្មី និងការនាំឈើចេញដោយល្មើសច្បាប់ នៅតាមបណ្តោយព្រំដែនទាំងអស់ ក្នុងគោលដៅការពារអោយបានល្អនូវប្រព័ន្ធបរិស្ថានរួម ។

រាជរដ្ឋាភិបាលកម្ពុជា សូមសំដែងនូវក្តីសង្ឃឹមជឿជាក់យ៉ាងមុតមាំថានឹងទទួលបាននូវការអបអរសាទរ និងការជួយឧបត្ថម្ភគាំទ្រយ៉ាងទូលំទូលាយពីសាធារណមតិជាតិ និងអន្តរជាតិ ដើម្បីបព្វហេតុដ៏ឧត្តុង្គឧត្តមនេះ ។

នាយករដ្ឋមន្ត្រីទី ១ នាយករដ្ឋមន្ត្រីទី ២
ព្រះហស្តលេខា និងត្រា ហត្ថលេខា និងត្រា
នរោត្តម រណឫទ្ធិ **ហ៊ុន សែន**

* * *

៣_សេចក្តីសំរេច

រាជធានីភ្នំពេញ ,ថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ១៩៩៦

សេចក្តីសំរេច លេខ : ៤២ សសរ

ស្តីពី

ការបង្កើតគណៈកម្មការចំរុះសំរាប់

ការអនុវត្តន៍ច្បាប់មនុស្សធម៌អន្តរជាតិ

* * *

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា នស/រកត/១០៩៤/៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីកាកែសំរួលសមាសភាពរាជរដ្ឋាភិបាល

- បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ចុះថ្ងៃទី ១៩ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤
- តាមសំណើរបស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

សំរេច

ប្រការ ១ : បង្កើតគណៈកម្មការមានឈ្មោះថា «គណៈកម្មការចំរុះសំរាប់ការអនុវត្តន៍ច្បាប់មនុស្សធម៌អន្តរជាតិ» ដែលមានសមាសភាពដូចតទៅ ÷

១–ឯកឧត្តម រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ជាប្រធាន
២–ឯកឧត្តម រដ្ឋលេខាធិការ ឬ អនុរដ្ឋលេខាធិការក្រសួងការពារជាតិ ជាអនុប្រធាន
៣–ឯកឧត្តមរដ្ឋលេខាធិការ ឬ អនុរដ្ឋលេខាធិការក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ជាអនុប្រធាន
៤–តំណាងក្រសួងមហាផ្ទៃ «ថ្នាក់នាយកដ្ឋាន» ជាសមាជិក
៥–តំណាងទីស្តីការគណៈរដ្ឋមន្ត្រី «ថ្នាក់នាយកដ្ឋាន» ជាសមាជិក
៦–តំណាងក្រសួងសុខាភិបាល «ថ្នាក់នាយកដ្ឋាន» ជាសមាជិក
៧–តំណាងកាកបាទក្រហមកម្ពុជា «ថ្នាក់នាយកដ្ឋាន» ជាសមាជិក
៨–តំណាងមជ្ឈមណ្ឌលសកម្មភាពមីនកម្ពុជា «ថ្នាក់នាយកដ្ឋាន» ជាសមាជិក
៩–តំណាងក្រសួងអប់រំ យុវជន និងកីឡា «ថ្នាក់នាយកដ្ឋាន» ជាសមាជិក
១០–តំណាងក្រសួងពត៌មាន «ថ្នាក់នាយកដ្ឋាន» ជាសមាជិក
១១–មន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ជាសមាជិក

ប្រការ ២ : គណៈកម្មការចំរុះសំរាប់ការអនុវត្តន៍ច្បាប់មនុស្សធម៌អន្តរជាតិមានភារកិច្ចដូចខាងក្រោម ÷

១–សិក្សានិងផ្តល់យោបល់ និងពិនិត្យលទ្ធភាពជាក់ស្តែងចូលជាភាគីក្នុងកិច្ច ព្រមព្រៀងនានាស្តីពីច្បាប់មនុស្សធម៌អន្តរជាតិ ដែលកម្ពុជាយើងមិនទាន់បានចូល ដូចជា :

ក/ពិធីសារបន្ថែម I និង II នៃអនុសញ្ញាទីក្រុងហ្សឺណែវ ស្តីពីការការពារជនរងគ្រោះក្នុងសង្គ្រាមអន្តរជាតិ និងជំលោះប្រដាប់អាវុធក្នុងស្រុក ។

ខ/អនុសញ្ញា និងពិធីសាររបស់អង្គការសហប្រជាជាតិ ស្ដីពីការហាមប្រាម ឬ កំរិតការប្រើប្រាស់ប្រភេទអាវុធមួយចំនួន ជាពិសេសពិធីសារ ស្ដីពីមីនប្រឆាំងមនុស្ស (Anti pcrsonal Landmincs) ។

គ/ ឯកសារអន្តរជាតិដទៃទៀត ។

២–ផ្ដល់យោបល់ពិគ្រោះពីវិធានការជាតិ សំរាប់ការអនុវត្តន៍ និង ពង្រឹងច្បាប់មនុស្សធម៌ ដូចជា :

ក/ពង្រាងច្បាប់ជាតិប្រកាសដាក់អោយប្រើប្រាស់ច្បាប់មនុស្សធម៌អន្តរជាតិ ។

ខ/ពង្រាងច្បាប់ ឬ វិសោធនកម្មលើច្បាប់ព្រហ្មទណ្ឌ ស្ដីពីការផ្ដន្ទាទោសអ្នករំលោភច្បាប់មនុស្សធម៌ ។

គ/លើកគំរោងស្ដីពីការផ្សព្វផ្សាយច្បាប់មនុស្សធម៌ ជាពិសេសការរៀបចំគោលការណ៍ណែនាំសំរាប់កងកំលាំងប្រដាប់អាវុធយើង និង បញ្ចូលកម្មវិធីគោលការណ៍សំខាន់ៗនៃច្បាប់ មនុស្សធម៌ក្នុងកាលវិភាគនៃការហ្វឹកហ្វឺននិង ការបណ្ដុះបណ្ដាលផ្សេងៗ ។

ឃ/ធ្វើជាចំណុចទំនាក់ទំនងនិងសំរបសំរួលជាមួយអង្គការជាតិអន្តរជាតិ ជាពិសេសអង្គការសហប្រជាជាតិ និងគណៈកម្មាធិការកាកបាទក្រហមអន្តរជាតិ (CICR) ។

៣–ធ្វើរបាយការណ៍ ជូនរាជរដ្ឋាភិបាលតាមកាលកំណត់ ។

ប្រការ ៣ : សមាជិកគណៈកម្មការចំរុះសំរាប់ការអនុវត្តន៍ច្បាប់មនុស្សធម៌អន្តរជាតិ ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន ឬ អនុប្រធានក្នុងករណីអនុវត្តមានរបស់ប្រធាន ។

ប្រការ ៤ : គណៈកម្មការចំរុះសំរាប់ការអនុវត្តន៍ច្បាប់មនុស្សធម៌អន្តរជាតិ មានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងយុត្តិធម៌ ។

ប្រការ ៥ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ សហរដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសុខាភិបាល ប្រធានកាកបាទក្រហម

កម្ពុជានិងប្រធានមជ្ឈមណ្ឌល សកម្មភាពមីនកម្ពុជា ត្រូវសហការអនុវត្តសេចក្តីសំរេចនេះ អោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃឡាយព្រះហស្តលេខា និងចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី ១ នាយករដ្ឋមន្ត្រីទី ២
ព្រះហស្តលេខានិងត្រា ហត្ថលេខានិងត្រា
នរោត្តម រណឫទ្ធិ ហ៊ុន សែន

* * *

រាជធានីភ្នំពេញ ;ថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ១៩៩៦

សេចក្តីសំរេច លេខ : ៤៣ សសរ

ស្តីពីការផ្ទេរសិទ្ធិ

* * *

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែង តាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត ១០៩៤/៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- តាមសំណើរបស់ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ ។

សំរេច

ប្រការ ១ : តែងតាំងឯកឧត្តម **សុខ អាន** សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ជារដ្ឋមន្ត្រីទីស្តីនៃក្រសួងវប្បធម៌និងវិចិត្រសិល្បៈក្នុងឱកាសដែលឯកឧត្តម **នុត ណារ៉ាង**

អញ្ជើញ ទៅបំពេញទស្សនកិច្ចនិងចុះហត្ថលេខាលើកិច្ចព្រមព្រៀង សហប្រតិបត្តិការវិស័យវប្បធម៌ ឆ្នាំ ១៩៩៧ រវាងក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ កម្ពុជា និង ក្រសួងឃោសនាការវប្បធម៌ឡាវនៅសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ដែលប្រព្រឹត្តិទៅចាប់ពីថ្ងៃទី ៤ ខែ តុលា ឆ្នាំ ១៩៩៦ នេះតទៅ ។

ប្រការ ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីគ្រប់ក្រសួង រដ្ឋលេខាធិការគ្រប់រដ្ឋ លេខាធិការដ្ឋាន និង ឯកឧត្តម **សុខ អាន** ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសំរេចនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃឡាយព្រះហស្ថលេខា និង ចុះហត្ថលេខានេះតទៅ ។

នាយករដ្ឋមន្ត្រីទី ១	**នាយករដ្ឋមន្ត្រីទី ២**
ព្រះហស្ថលេខានិងត្រា	ហត្ថលេខានិងត្រា
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

* * *

៤_សារាចរ

រាជធានីភ្នំពេញ ,ថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ១៩៩៦

សារាចរ លេខ : ០៦ សរ

ស្តីពីការចាត់តាំងរៀបចំពិធីបុណ្យចំរើនព្រះជន្មព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ក្នុងគម្រប់ព្រះជន្ម ៧៤ យាង ចូល ៧៥ ព្រះវស្សា បុណ្យខួបអនុស្សាវរីយ៍លើកទី ៤៣ នៃទិវាបុណ្យឯករាជ្យជាតិ ៩ វិច្ឆិកា និងបុណ្យអុំទូក បណ្តែតប្រទីប សំពះព្រះ ខែ អកអំបុក

* * *

* ពិធីបុណ្យចំរើនព្រះជន្មព្រះករុណា ព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ជាទីគោរពសក្ការៈ ក្នុងគម្រប់ព្រះជន្ម ៧៤ យាងចូល ៧៥ ព្រះវស្សានឹងត្រូវប្រព្រឹត្តទៅចំនួន ៣ ថ្ងៃ ចាប់ពីថ្ងៃទី៣០–៣១ តុលា

ដល់ ០១ វិច្ឆិកា ៨៦ ខាងមុខនេះ ដើម្បីសំដែងកតញ្ញូតាធម៌ចំពោះ ព្រះមហាករុណាទិគុណថ្វាយព្រះពរសព្ទសាធុការ និង ថ្វាយមហាកុសលចំពោះព្រះករុណាជាអម្ចាស់ជីវិតលើត្បូងទ្រង់មានព្រះជន្មាយុយឺនយូរ ព្រះសុខមាលភាពល្អបរិបូណ៌ ព្រះកាយពលរឹងមាំ និង ព្រះបញ្ញាញាណភ្លឺថ្លា ដើម្បីបានគង់ប្រថាប់នៅជាម្លប់ដ៏ត្រជាក់របស់ប្រជារាស្ត្រខ្មែរយូរអង្វែងតរៀងទៅ ។

* ពិធីបុណ្យខួបអនុស្សាវរីយ៍លើកទី ៤៣ នៃទិវាបុណ្យឯករាជ្យជាតិ នឹងត្រូវប្រព្រឹត្តទៅនៅ ថ្ងៃទី ០៩ ខែ វិច្ឆិកា ឆ្នាំ ១៩៨៦ ដើម្បីសំដែងមនោសញ្ចេតនាអបអរសាទរវិលើកទិជាប្រវត្តិសាស្ត្រដែលកំលាំងមហាមត្តីជាតិទាំងមូល ផណ្តើមបានទាំងស្រុងមកវិញពីអាណានិគមនិយមបារាំង នាឆ្នាំ ១៩៥៣ នូវឯករាជ្យជាតិដ៏ពិតប្រាកដក្រោមព្រះរាជបូជនីយកិច្ចដ៏ថ្លៃថ្លា នៃព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃ ព្រះរាជាណាចក្រកម្ពុជា ។

* ពិធីបុណ្យអុំទូក បណ្តែតប្រទីប សំពះព្រះខែ និងអកអំបុក នឹងត្រូវប្រព្រឹត្តទៅចំនួន ៣ ថ្ងៃគឺថ្ងៃទី ២៤–២៥–២៦ វិច្ឆិកា ១៩៨៦ ដើម្បីបើកឱកាសជូនប្រជារាស្ត្រសប្បាយរីករាយ ចូលរួមថែរក្សានូវប្រពៃណីរបស់ជាតិ ដែលជាប់ទាក់ទងទៅនឹងប្រវត្តិពិធីសមយុទ្ធនៃកំលាំង សាមគ្គីកងទ័ពជើងទឹករបស់យើង ក្នុងបុព្វហេតុការពារមាតុភូមិ និងសំដែងមនោសញ្ចេតនា ប្រកបដោយកតញ្ញូតាធម៌ចំពោះមហាករុណាទិគុណនៃព្រះរតនត្រ័យ ពពួកទេវតា និងវត្ថុសក្តិសិទ្ធិដែលបានគាំពារ និងជួយឧបត្ថម្ភអោយវិស័យកសិកម្មជាតិ មានការចំរើនរុងរឿងព្រមទាំងជាឱកាសបួងសួងសុំអោយ បារមីនៃព្រះពុទ្ធជាអម្ចាស់និងវត្ថុសក្តិសិទ្ធិទាំងនោះ បន្តជួបឧបត្ថម្ភវិស័យកសិកម្ម នារដូវខាងមុខអោយទទួលបានជោគជ័យ និង ទិន្នផលខ្ពស់ជាងនេះថែមទៀត ។

ដើម្បីចាត់តាំងរៀបចំពិធីបុណ្យទាំងបីអោយបានសមរម្យ សក្តិសមទៅនឹងអត្ថន័យដ៏ជ្រាលជ្រៅដូចបានបញ្ជាក់ខាងលើនេះ រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាសូមធ្វើការណែនាំដូចតទៅនេះ ÷

១—ពិធីបុណ្យចំរើនព្រះជន្មវស្សា

—គណៈកម្មការអចិន្ត្រៃយ៍រៀបចំបុណ្យជាតិ អន្តរជាតិ សហការជាមួយក្រសួងព្រះបរមរាជវាំង ត្រូវចាត់តាំងពិធីបុណ្យចំរើនព្រះជន្មព្រះករុណាជាអម្ចាស់ជីវិតលើត្បូង នៅក្នុងព្រះបរមរាជវាំងអោយបានឧឡារិក អធិកអធម ស្របតាមប្រពៃណីជាតិ និងប្រពៃណីសាសនា ដោយមានថ្នាក់ដឹកនាំ ព្រះរាជវង្សានុវង្ស មន្ត្រីរាជការ អ្នកមុខអ្នកការ គ្រប់តំណែងគ្រប់ក្រសួង រដ្ឋលេខាធិការដ្ឋាន ស្ថាប័ន និង ខេត្ត ក្រុង ចូលរួមថ្វាយព្រះពរ ។

—គ្រប់ខេត្ត ក្រុង ត្រូវចាត់តាំងរៀបចំពិធីបុណ្យចំរើនព្រះជន្មព្រះករុណាជា អម្ចាស់ជីវិតលើត្បូងក្នុងក្របខ័ណ្ឌ ខេត្ត ក្រុង របស់ខ្លួនអោយបានឧឡារិកដោយមានមន្ត្រីរាជការថ្នាក់ដឹកនាំខេត្ត_ក្រុង មន្ទីរនានា ជុំវិញខេត្ត ក្រុង ខ័ណ្ឌ ស្រុក អ្នកមុខអ្នកការ ព្រះសង្ឃ និងប្រជារាស្ត្រចូលរួមថ្វាយព្រះពរ ។

—គ្រប់ក្រសួង រដ្ឋលេខាធិការដ្ឋាន ស្ថាប័នរដ្ឋ និងឯកជន និងខេត្ត ក្រុង ត្រូវរៀបចំតាំងព្រះឆាយាលក្ខណ៍ ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង តុបតែងលំអ រចនាដោយភ្លើងពណ៌ និងពាក្យស្លោកថ្វាយព្រះពរ ។ នៅពេលយប់មានចាត់តាំងក្រុមតន្ត្រី សិល្បៈបុរាណ សម័យសំដែងជូនប្រជារាស្ត្រទស្សនាកំសាន្តសប្បាយ នៅតាមទីធ្លាសាធារណៈ ។

២—ពិធីបុណ្យឯករាជ្យជាតិ

—ត្រូវចាត់តាំងរៀបចំពិធីបុណ្យខួបអនុស្សាវរីយ៍លើក៤៣ នៃទិវាឯករាជ្យជាតិ ៩ វិច្ឆិកា ក្នុងកិរិតជីសមរម្យ សក្តិសមទៅនឹងកិត្តិយសប្រទេសជាតិ ដោយមានចាត់តាំងពិធីដុតទៀនជ័យ ដាក់កម្រងផ្កាគោរពវិញ្ញាណក្ខ័ន្ធ និងពន្លត់ទៀនជ័យនៅវិមានឯករាជ្យ ព្រមទាំងមានបង្ហោះប៉េងប៉ោង លែងព្រាបជានិមិត្តរូបនៃការសុំសុខសន្តិភាពផង ។

—ខេត្ត ក្រុង ត្រូវចាត់តាំងពិធីគោរពវិញ្ញាណក្ខ័ន្ធនៅតាមទីកន្លែងជីសមគួរ តាមការជាក់ស្តែងរបស់ខេត្ត ក្រុង នីមួយៗ ។

—គណៈកម្មការអចិន្ត្រៃយ៍រៀបចំបុណ្យជាតិ អន្តរជាតិ ត្រូវរៀបចំកម្មវិធីសំរាប់ថ្នាក់ដឹកនាំក្រសួងរដ្ឋលេខាធិការដ្ឋាន ស្ថាប័ន ចុះសួរសុខទុក្ខកងយោធពលខេមរភូមិន្ទនៅសមរភូមិ របួសកំពុងសំរាកព្យាបាល នៅតាមមន្ទីរពេទ្យ មណ្ឌលយុទ្ធជនពិការ ដោយមាននាំ អំណោយជួយឧបត្ថម្ភ និងបំផុសអោយគ្រប់ក្រសួង រដ្ឋលេខាធិការដ្ឋាន ស្ថាប័ន ចងបដាពាក្យស្លោកដោតទង់ជាតិ ទង់ក្លែបនិងតុបតែងលំអភ្លើងពណ៌ អោយបានឧឡារិក ។

៣—ពិធីបុណ្យអុំទូក បណ្តែតប្រទីប សំពះព្រះខែ អកអំបុក :

—គណៈកម្មការអចិន្ត្រៃយ៍រៀបចំបុណ្យជាតិ អន្តរជាតិ សហការជាមួយក្រសួងពាក់ព័ន្ធ និង ខេត្ត ក្រុង ចាត់តាំងរៀបចំពិធីបុណ្យអុំទូក បណ្តែតប្រទីប សំពះព្រះខែ អកអំបុក នៅតាមដងទន្លេសាបនៅវេទិកាអុំទូក មុខព្រះបរមរាជវាំង ក្នុងរយៈកាល ៣ ថ្ងៃ តាមប្រពៃ ណីជាតិប្រពៃណីសាសនា ដោយមានចាត់តាំងក្រសួងមួយចំនួន រចនាតុបតែងជាប្រទីប មានអុចកាំជ្រួចភ្លឺទៀន មានតាំងភ្លើងពណ៌រន្ទាលប្រាលផ្លោនៅរាជធានីភ្នំពេញ ។

—គណៈកម្មការអចិន្ត្រៃយ៍រៀបចំបុណ្យជាតិ អន្តរជាតិ ត្រូវមានផែនការណែនាំលំអិតជាក់ស្តែង ស្តីពីល័ក្ខខ័ណ្ឌទាំងឡាយនៃការជ្រើសរើសទូកង ដែលត្រូវចូលរួមប្រណាំង ដោយត្រូវកំណត់ទូកអុំ ទូកចែវ អោយបានច្បាស់លាស់ និងត្រូវធ្វើសេចក្តីអំពាវនាវសប្បុរសជន បណ្តាក្រុមហ៊ុនឯកជនអោយជួយឧបត្ថម្ភជា សំភារៈ ថវិកា សំរាប់ជូនរង្វាន់ដល់កីឡាករអុំទូក ។

—ខេត្ត ក្រុង ដែលមានទូកង ចូលរួមប្រណាំង ត្រូវធ្វើការសាកល្បងចម្រាញ់ជ្រើសរើសទូក ដែលមានចំណាត់ថ្នាក់ជាទូកលឿនរបស់ខេត្ត ក្រុង ក្នុងចំនួនសមរម្យ សំរាប់ចូលរួមប្រណាំងនៅរាជធានីភ្នំពេញ ។

—ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ត្រូវចាត់តាំងរៀបចំកម្មវិធីសិល្បៈ និងចំរៀងសម័យបុរាណ សំដែងជូនប្រជារាស្ត្រទស្សនាកំសាន្តនៅតាមទីសាធារណៈ អបអរសាទរក្នុងពិធី បុណ្យទាំងបីខាងលើ ។ ខេត្ត ក្រុង ក៏ត្រូវមានចាត់តាំងសិល្បៈសំដែងជូនប្រជារាស្ត្រទស្សនា កំសាន្តដូចនៅរាជធានីភ្នំពេញដែរ ។

—ទីស្តីការគណៈរដ្ឋមន្ត្រី និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវត្រៀមលក្ខណៈដោះស្រាយសំភារៈនិងថវិកាសំរាប់បំរើការរៀបចំពិធីបុណ្យទាំងបីខាងលើ អោយបានសមស្របនិងទាន់ពេលវេលា ។

—គណៈកម្មការអចិន្ត្រៃយ៍រៀបចំបុណ្យជាតិ អន្តរជាតិ ត្រូវបូកសរុបគំរោងថវិកាចំណាយលំអិតដែលក្រសួងពាក់ព័ន្ធបានលើកឡើង ក្នុងស្មារតីសន្សំសំចៃ ថ្លៃប្រឹងខ្ពស់ ផ្ញើជូនរាជរដ្ឋាភិបាលដើម្បីពិនិត្យ និងសំរេច ។

ទទួលបានសារាចរនេះ សូមឯកឧត្តមរដ្ឋមន្ត្រី រដ្ឋលេខាធិការ ប្រធានស្ថាប័ន គ្រប់ក្រសួងគ្រប់រដ្ឋលេខាធិការដ្ឋាន ស្ថាប័នពាក់ព័ន្ធ និងអភិបាល ខេត្ត ក្រុង ចាត់តាំងអនុវត្តអោយ

បានសំរេចលទ្ធផលល្អប្រសើរ ស្របតាមគោលបំណងនិងសំណូមពរ ហើយធ្វើរបាយការណ៍បូក សរុបជូនរាជរដ្ឋាភិបាល ។

នាយករដ្ឋមន្ត្រីទី ១	នាយករដ្ឋមន្ត្រីទី ២
ព្រះហស្តលេខានិងត្រា	ហត្ថលេខានិងត្រា
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

* * *

III - ការងារបណ្តាក្រសួង

ប្រកាសអន្តរក្រសួង

១_ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ក្រសួងធម្មការ និងសាសនា

រាជធានីភ្នំពេញ ,ថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ១៩៩៦

ប្រកាស លេខ : ៥៧៩ សហ.វម.ប្រក

ប្រកាសអន្តរក្រសួង

ស្តីពីការបង្កើតរដ្ឋបាលឲ្យប្រវត្តិប្រធាននៅ

ក្រសួងធម្មការ និងសាសនា

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

រដ្ឋលេខាធិការ ក្រសួងធម្មការ និងសាសនា

* * *

– បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

- យោងព្រះរាជក្រឹត្យរបស់ ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុវរ្ម័ន** ព្រះមហាក្សត្រ នៃ ព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១១៩៩៣ ស្តីពីការតែងតាំងរដ្ឋាភិបាលកម្ពុជា
- យោងព្រះរាជក្រឹត្យលេខ នស.រកត ប១០៩៤.៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាព រាជរដ្ឋាភិបាល
- បានឃើញច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៥
- បានឃើញច្បាប់ស្តីពីការប្រពន្ធ័ហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម លេខ ០១ ន.ស ចុះថ្ងៃទី ២៨ ធ្នូ ឆ្នាំ ១៩៩៣
- បានឃើញច្បាប់ហិរញ្ញវត្ថុសំរាប់ឆ្នាំ ១៩៩៥ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម លេខ ១១ នស ៩៤ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤
- បានឃើញអនុក្រឹត្យលេខ ៨២ អ.ន.ក្រ.ប.ក ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ ស្តីពី បទបញ្ញា ទូទៅ នៃ គណនេយ្យ សាធារណៈ
- បានឃើញប្រកាសលេខ ០០៤ ស.ហ.វ.ម.ប្រ.ក ចុះថ្ងៃទី ១៥ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការអនុវត្តន៍ បទបញ្ញាទូទៅ នៃគណនេយ្យសាធារណៈ
- បានឃើញលិខិតលេខ ១១៥ ស.ហ.វ.ម ចុះថ្ងៃទី ១៦ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការអនុវត្តបទបញ្ញាទូទៅ នៃគណនេយ្យសាធារណៈ
- បានឃើញសារាចរណែនាំលេខ ០០៣ សហវម ចុះថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ ១៩៩៦ ស្តីពីការប្រព្រឹត្តិទៅនៃ រជ្ជទេយ្យបុរេប្រទាន
- បានឃើញតំរូវការចាំបាច់នៃការងាររដ្ឋកិច្ច និង ហិញ្ញវត្ថុបច្ចុប្បន្ន

សំរេច

ប្រការ ១ : ត្រូវបានបង្កើតរជ្ជទេយ្យបុរេប្រទាននៅក្រសួង ធម្មការនិងសាសនា ដើម្បីទូទាត់ចំណាយទាំងឡាយដែលមានចែងក្នុងមាត្រា ៦៤ នៃអនុក្រឹត្យលេខ ៨២ អន.ក្របក ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ ស្តីអំពីបទបញ្ញាទូទៅនៃគណនេយ្យសាធារណៈ ។ ចំនួនទឹកប្រាក់ជាអតិបរមានៃចំណាយដែលអនុញ្ញាតអោយរជ្ជទេយ្យបុរេប្រទានធ្វើការទូទាត់ ត្រូវកំណត់ដោយទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

ប្រការ ២ : ចំនួនទឹកប្រាក់នៃវត្ថុទេយ្យ បុរេប្រទានត្រូវបានកំណត់ត្រឹមចំនួន ៣.៧៧៩.០០០ រៀល ។

ប្រការ ៣ : ខុទ្ទកាល័យ មន្ទីរ រតនាគារជាតិ នាយកដ្ឋាន ព្រមទាំងអង្គភាពពាក់ព័ន្ធទាំងអស់ក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និង ក្រសួងធម្មការ និង សាសនា មានភារកិច្ចទទួលបន្ទុកអនុវត្តប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋលេខាធិការក្រសួងធម្មការ	រដ្ឋលេខាធិការក្រសួង
និងសាសនា	សេដ្ឋកិច្ច និងហិរញ្ញវត្ថុ
ហត្ថលេខានិងត្រា	ហត្ថលេខានិងត្រា
ហឿន វណ្ណរ័ត្ន	**ស៊ុន ចាន់ថុល**

* * *

២_ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
ក្រសួងផែនការ

រាជធានីភ្នំពេញ ,ថ្ងៃទី ២១ ខែ តុលា ឆ្នាំ ១៩៩៦

ប្រកាស លេខ : ៣១៩ ស.ហ.វ.ម.ប្រក

ប្រកាសអន្តរក្រសួងស្តីពី

ការបង្កើតវត្ថុទេយ្យចំណូលនៅក្រសួងផែនការ

ទេសរដ្ឋមន្ត្រីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

រដ្ឋមន្ត្រីក្រសួងផែនការ

* * *

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- យោងព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះនរោត្តម **សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

- យោងព្រះរាជក្រឹត្យលេខ នស.រកត ១០៩៤.៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើប្រាស់ដោយព្រះរាជក្រម លេខ ០១ ន.ស ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣
- បានឃើញច្បាប់ហិរញ្ញវត្ថុសំរាប់ឆ្នាំ ១៩៩៥ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម លេខ ១១
- បានឃើញអនុក្រឹត្យលេខ ៨២ អ.ន.ក្រ.ប.ក ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ ស្តីពីបទបញ្ញាទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញប្រកាសលេខ ០០៤ ស.ហ.វ.ម.ប្រ.ក ចុះថ្ងៃទី ១៥ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការអនុវត្តន៍បទបញ្ញាទូទៅនៃគណៈនេយ្យសាធារណៈ
- បានឃើញលិខិតលេខ ១១៥ ស.ហ.វ.ម ចុះថ្ងៃទី ១៦ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការអនុវត្តន៍បទបញ្ញាទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញសារាចរណែនាំលេខ ០០២ ស.ហ.វ.ម ចុះថ្ងៃទី ១៦ កុម្ភៈ ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតរដ្ឋនេយ្យចំណូល
- បានឃើញតំរូវការចាំបាច់នៃការងារសេដ្ឋកិច្ច និង ហិរញ្ញវត្ថុបច្ចុប្បន្ន

សំរេច

ប្រការ ១ : ត្រូវបានបង្កើតរដ្ឋនេយ្យចំណូលនៅក្រសួង ផែនការ ដើម្បីធ្វើការប្រមូលនូវចំណូលដូចតទៅនេះ ចំណូលពីការជួលអាគារ ០១ ខ្នង (បីពាន់ប្រាំរយដុល្លារអាមេរិក ៣.៥០០ ដុល្លារក្នុងមួយ ខែ) ។

ប្រការ ២ : ចំនួនទឹកប្រាក់អតិបរមា ដែលអនុញ្ញាតទុកនៅក្នុងបេឡាមានកំណត់ត្រឹម ចំនួនពីរលានរៀល (២.០០០.០០០រ) ។

ប្រការ ៣ : សេចក្តីសំរេចទាំងឡាយណាដែលផ្ទុយ និង ប្រកាសនេះត្រូវចាត់ទុកជានិរាករណ៍ ។

ប្រការ ៤ មន្ទីរ រតនាគារជាតិ នាយកដ្ឋាន ព្រមទាំងអង្គភាពពាក់ព័ន្ធទាំងអស់ក្រោមឱវាទ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និង ក្រសួងផែនការ ត្រូវទទួលបន្ទុកអនុវត្តតាមប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋមន្ត្រីក្រសួងផែនការ	រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច ហិរញ្ញវត្ថុ
ហត្ថលេខានិងត្រា	ហត្ថលេខានិងត្រា
ជា ចាន់តូ	**ស៊ុន ចាន់ថុល**

រាជធានីភ្នំពេញ ,ថ្ងៃទី ២១ ខែ តុលា ឆ្នាំ ១៩៩៦

ប្រកាស លេខ ៦២០ .ស.ហ.វ.ម.ប្រក

ប្រកាសអន្តរក្រសួង

ស្តីពីការតែងតាំងវិជ្ជាធរប្រចាំឈ្នួលនៅក្រសួងផែនការ

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

រដ្ឋមន្ត្រីក្រសួងផែនការ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- យោងព្រះរាជក្រឹត្យរបស់ ព្រះករុណាព្រះបាទសម្តេច **នរោត្តម សីហនុវរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- យោងព្រះរាជក្រឹត្យលេខ នស.រកត ១០៩៤.៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើប្រាស់ដោយព្រះរាជក្រម លេខ ០១ ន.ស ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣

- បានឃើញច្បាប់ហិរញ្ញវត្ថុសំរាប់ឆ្នាំ ១៩៩៥ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម លេខ ១១ ន.ស ៩៤ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤
- បានឃើញអនុក្រឹត្យលេខ ៨២ អ.ន.ក្រ.ប.ក ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ ស្តីពីបទបញ្ជាទូទៅនៃគណៈនេយ្យសាធារណៈ
- បានឃើញប្រកាសលេខ ០០៤ ស.ហ.វ.ម.ប្រ.ក ចុះថ្ងៃទី ១៥ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការអនុវត្តន៍បទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញលិខិតលេខ ១១៥ ស.ហ.វ.ប្រ.ក ចុះថ្ងៃទី ១៦ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការអនុវត្តន៍បទបញ្ញាទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញសារាចរណែនាំលេខ ០០២ ស.ហ.វ.ប្រ.ក ចុះថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតរដ្ឋទេយ្យចំណូល
- បានឃើញតំរូវការចាំបាច់នៃការងារសេដ្ឋកិច្ច និង ហិរញ្ញវត្ថុបច្ចុប្បន្ន

សំរេច

ប្រការ ១ : ត្រូវបានតែងតាំងលោក **គោះ សំអុល** ឋានៈ តួនាទី អនុប្រធានមន្ទីរក្រសួងផែនការអោយ ទទួលការងារបច្ចុប្បន្នជារដ្ឋទេយ្យករចំណូលនៅអមក្រសួងផែនការ ។

ប្រការ ២ : ការតែងតាំងនេះមានប្រសិទ្ធភាពចាប់ពីថ្ងៃទី ០១ ខែ កក្កដា ឆ្នាំ ១៩៩៦ នេះតទៅ ។

ប្រការ ៣ : សេចក្តីសំរេចទាំងឡាយណា ដែលផ្ទុយនឹងប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

ប្រការ ៤ : មន្ទីរ រតនាគារជាតិ នាយកដ្ឋាន ព្រមទាំងអង្គភាពពាក់ព័ន្ធទាំងអស់ក្រោមឱវាទក្រសួងសេដ្ឋ កិច្ចនិងហិរញ្ញវត្ថុ និង ក្រសួងផែនការ ព្រមទាំងលោក **គោះ សំអុល** ត្រូវទទួលបន្ទុក អនុវត្ត តាមប្រកាសនេះចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋមន្ត្រីក្រសួងផែនការ	រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច ហិរញ្ញវត្ថុ រដ្ឋលេខាធិការ
ហត្ថលេខានិងត្រា	ហត្ថលេខានិងត្រា
ជា ចាន់តូ	**ស៊ុន ចាន់ថុល**

* * *

៣_ទីស្តីការរដ្ឋមន្ត្រីក្រសួងឧស្សាហកម្មរ៉ែ និង ថាមពល

ប្រកាស

ប្រកាស លេខ : ៥៩៥ ឧក.ប្រក ចុះថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ១៩៩៦

ប្រការ ១ : អនុញ្ញាតអោយលោក **គុយ ហេង** ជនជាតិ ខ្មែរ សញ្ជាតិ កម្ពុជា កាន់អត្តសញ្ញាណប័ណ្ណ លេខ ០០១១៤៨ ព.វ ចុះថ្ងៃទី ១៨–១១–៨៥ អាស័យដ្ឋានបច្ចុប្បន្ន ភូមិ ពោធិចិន្តាំ ឃុំ ស្វាយអន្ទរ ស្រុក ព្រៃវែង ខេត្ត ព្រៃវែងបើកដំណើរការរោងម៉ាស៊ីនកិនស្រូវ កំលាំង ១២០ សេះ នៅក្នុង ទីតាំង ដូចអាស័យដ្ឋានខាងលើ ។

ប្រការ ២ : លោក **គុយ ហេង** ត្រូវចាប់ផ្តើមដំណើរការផលិតកម្ម អាជីវកម្មលើទីតាំងដូចបានកំណត់ក្នុងប្លង់ ដោយធានានូវទិន្នផលអង្ករលេខ ១ អោយបានយ៉ាងតិចបំផុត ៦៥ ភាគរយ ។

